អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

**អង្គភាពគាំពារជនរងគ្រោះ**
**Victims Support Section**
**Section d'appui aux victims**

ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១១

**<u>សេចក្តីរំលឹកព័ត៌មាន</u>**

**អង្គភាពគាំពារជនរងគ្រោះរៀបចំវេទិកាថ្នាក់តំបន់លើកទី៧ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ៣៥០ នាក់ នៃសំណុំរឿង ០០២ នៅខេត្តកំពង់ធំ**

អង្គភាពគាំពារជនរងគ្រោះ (VSS) នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) កំពុងរៀបចំវេទិកាថ្នាក់តំបន់លើកទី៧ របស់ខ្លួន សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣៥០ នាក់ ដែលថ្មីៗនេះត្រូវបានទទួលស្គាល់នៅក្នុងសំណុំរឿង ០០២។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះមកពីខេត្តកំពង់ធំ សៀមរាប ឧត្តរមានជ័យ និងបណ្តាខេត្តនៅភាគនិរតីបឹងទន្លេសាប។ វេទិកានេះនឹងត្រូវរៀបចំនៅ<u>សាលាខេត្តកំពង់ធំ</u> ***នៅថ្ងៃព្រហស្បត្តិ៍ ទី១១ ខែសីហា ឆ្នាំ២០១១ ចាប់ពីម៉ោង ៧:៣០ នាទីព្រឹក*** *(អត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានរក្សាការសម្ងាត់)*។

អ្នកចូលរួមទាំង ៣៥០ នាក់ នៅក្នុងវេទិកាថ្នាក់តំបន់នេះ គឺជាផ្នែកនៃក្រុមដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១.៧២៨ នាក់ ដែលអង្គបុរេជំនុំជម្រះបានទទួលស្គាល់នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១។ បច្ចុប្បន្ន នៅក្នុងសំណុំរឿង ០០២ មានដើមបណ្តឹងរដ្ឋប្បវេណីសរុបចំនួន ៣.៨៦៦ នាក់។

វេទិកាថ្នាក់តំបន់គឺជាវិធីសាស្ត្រមួយដែលអង្គភាពគាំពារជនរងគ្រោះអនុវត្តគម្រោងរបស់ខ្លួន ស្តីពីការកែលម្អការចូលរួមរបស់ជនរងគ្រោះឲ្យបានទូលំទូលាយ នៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក នៅឆ្នាំ ២០១១ និងផ្តល់អំណាចដល់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការ ក្នុងសំណុំរឿង ០០២។ វេទិកាថ្នាក់តំបន់មានគោលបំណងលើកកម្ពស់ដល់ការចូលរួមរបស់ជនរងគ្រោះ ដោយផ្តល់នូវទីកន្លែងមានសុវត្ថិភាពសម្រាប់កិច្ចសន្ទនារបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមកពីបណ្តាខេត្តទាំងនោះ និងដើម្បី៖

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

- ជួបជាមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអំពីសិទ្ធិក្នុងដំណើរការជម្រះក្តី និងជាពិសេសប្រមូលគំនិតដែលពាក់ព័ន្ធនឹងសំណងជាសមូហភាព ដើម្បីរៀបចំគម្រោងទាមទារសំណងទាំងនោះ។
- ជួបជាមួយមន្ត្រីមកពីការិយាល័យនានានៃ អ.វ.ត.ក និងតំណាងសង្គមស៊ីវិល ដើម្បីស្វែងយល់ពីការវិវត្តថ្មីៗរបស់ អ.វ.ត.ក។ និង
- ជួបជាមួយដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០១ ដើម្បីចែករំលែកបទពិសោធន៍សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០២។

ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១១ អង្គភាពគាំពារជនរងគ្រោះបានរៀបចំវេទិកាថ្នាក់តំបន់ចំនួន ១០ លើកយ៉ាងជោគជ័យ ដោយមានការចូលរួមពីអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណីសរុបចំនួន ៣.៣១៥ នាក់ មកពីគ្រប់ទិសទីនៃព្រះរាជាណាចក្រកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក អ៊ឹម សុភា**
មន្ត្រីសម្របសម្រួល VSS/អ.វ.ត.ក
ទូរស័ព្ទ៖ +៨៥៥ (0) ៧៧ ៧៧៧ ៣៦៧
ទូរស័ព្ទលើតុ៖ +៨៥៥ (0) ២៣ ២១៩ ៨១៤ លេខបន្ត ៦៦០២
អ៊ីមែល៖ im.sophea@eccc.gov.kh



Original EN: 01699222-01699222